**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
**លេខ:** ០២០៤ រថ.បគអថ.ប្រក

# ប្រកាស
## ស្ដីពី
## នីតិវិធី និងលក្ខខណ្ឌនៃការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្ដល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្ដល់សេវាដំណោះស្រាយថាមពល

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០៣២១ រថ.អថ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានា នៃអគ្គនាយកដ្ឋានថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

# សម្រេច

# ជំពូកទី១

# បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធីនិងលក្ខខណ្ឌនៃការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងអ្នកធ្វើការនិងអ្នកផ្តល់សេវាខាងលើ ឱ្យមានការទទួលខុសត្រូវច្បាស់លាស់ មានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព និងមានការពង្រឹងនិងពង្រីកសមត្ថភាពបច្ចេកទេសជាប្រចាំ ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

អ្នកជំនាញ និងក្រុមហ៊ុន ដែលបំពេញតួនាទីណាមួយដែលមានកំណត់ក្នុងប្រការ១ខាងលើ ត្រូវមកចុះបញ្ជីនៅក្រសួងរ៉ែ និងថាមពល។

**ប្រការ ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

| | |
|---|---|
| ចុះបញ្ជី | សំដៅដល់ការដាក់ពាក្យស្នើសុំ ការអនុវត្តនីតិវិធីនិងលក្ខខណ្ឌចុះបញ្ជី និងបានទទួលវិញ្ញាបនបត្រចុះបញ្ជីពីក្រសួងរ៉ែ និងថាមពល។ |
| វិញ្ញាបនបត្រចុះបញ្ជី | សំដៅដល់វិញ្ញាបនបត្រទទួលស្គាល់ការចុះបញ្ជីបានជោគជ័យ។ |
| ថាមពល | សំដៅដល់ថាមពលអគ្គិសនី និងថាមពលចំហាយ។ |
| អ្នកគ្រប់គ្រងថាមពល | សំដៅដល់អ្នកជំនាញថាមពលដែលទទួលបន្ទុកជាអ្នកគ្រប់គ្រងលើការងារពាក់ព័ន្ធជាមួយប្រព័ន្ធប្រើប្រាស់ថាមពល នៅក្នុងទីតាំងប្រើប្រាស់ថាមពលណាមួយ។ |
| សវនករថាមពល | សំដៅដល់អ្នកជំនាញថាមពលដែលមានតួនាទីជាអ្នកត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍លើការប្រើប្រាស់ថាមពលឱ្យទីតាំងប្រើប្រាស់ថាមពល។ |
| អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល | សំដៅដល់អ្នកជំនាញដែលជាអ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ដែលរួមមានអ្នកធ្វើការងារជំនាញក្នុងផ្នែកផលិតកម្ម អ្នកធ្វើការងារជំនាញក្នុងផ្នែកបញ្ជូន អ្នកធ្វើការងារជំនាញក្នុងផ្នែកចែកចាយ រួមទាំងអ្នកធ្វើការងារជំនាញក្នុងសេវាកម្មបញ្ចូលថាមពលឱ្យយានយន្តអគ្គិសនី និងអ្នកធ្វើការងារជំនាញក្នុងផ្នែកប្រើប្រាស់អគ្គិសនីនៃវិស័យថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា។ |
| ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អ ប្រព័ន្ធថាមពល | សំដៅដល់ក្រុមហ៊ុនដែលជាអ្នកផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ។ ក្រុមហ៊ុនផ្តល់សេវាប្រភេទនេះអាចជាក្រុមហ៊ុនផ្តល់សេវាប្រភេទនេះទាំងអស់ ឬសេវានីមួយៗ ឬសេវាមួយចំនួន។ និយមន័យនៃសេវានីមួយៗ មានកំណត់នៅខាងក្រោម។ |
| សេវាដំឡើង | សំដៅដល់ការផ្តល់សេវាពិនិត្យ វិភាគ រចនាប្លង់ និងសាងសង់ និងដំឡើងប្រព័ន្ធថាមពល។ |

| | |
|---|---|
| សេវាថែទាំ ជួសជុល | សំដៅដល់ការផ្តល់សេវាពិនិត្យ វិភាគ វាយតម្លៃគុណភាពនិងសុវត្ថិភាព ជូតសម្អាត ជួសជុល និងផ្លាស់ប្តូរបរិក្ខារនៃប្រព័ន្ធថាមពល ។ |
| សេវាកែលម្អ | សំដៅដល់ការផ្តល់សេវាពិនិត្យ វិភាគ រចនាប្លង់ កែសម្រួល និងបំពាក់បរិក្ខារ នៃប្រព័ន្ធថាមពល។ |
| ប្រព័ន្ធថាមពល | សំដៅដល់មធ្យោបាយផលិត បញ្ជូន ចែកចាយ និងប្រើប្រាស់ថាមពល។ |
| អ្នកប្រើប្រាស់ | សំដៅដល់បុគ្គលណាមួយដែលទិញ ឬទទួលអគ្គិសនីដើម្បីយកទៅប្រើប្រាស់។ |
| ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល (ESCO) | សំដៅដល់ក្រុមហ៊ុនដែលធ្វើការងារផ្តល់សេវាដំណោះស្រាយបញ្ហាថាមពល រួមមាន ការអភិវឌ្ឍ ការងារសិក្សាគម្រោងប្លង់ និងការអនុវត្តគម្រោងសន្សំសំចៃថាមពល ការកែច្នៃ និងសេវាថាមពលផ្សេងទៀត ជូនដល់អ្នកប្រើប្រាស់ថាមពល។ |

## ជំពូកទី២
## តួនាទី និងភារកិច្ច

**ប្រការ ៤**.-

ក្រសួងរ៉ែ និងថាមពល ជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពលនៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងក្របខណ្ឌសមត្ថកិច្ចនៃការគ្រប់គ្រងការចុះបញ្ជីនេះ ក្រសួងរ៉ែ និងថាមពល មានភារកិច្ចដូចខាងក្រោម៖

១. រៀបចំចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ដើម្បីក្លាយជាអ្នកផ្តល់សេវាទាំងនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា

២. គ្រប់គ្រង និងរៀបចំការបណ្តុះបណ្តាលផ្នែកជំនាញពាក់ព័ន្ធជាមួយការផ្តល់សេវាទាំងនេះដល់អ្នកចុះបញ្ជី

៣. ផ្សព្វផ្សាយអំពីបច្ចេកទេស បច្ចេកវិទ្យា បរិក្ខារ បទពិសោធន៍ ស្តង់ដា និងការការពារសុវត្ថិភាពពាក់ព័ន្ធនឹងការផ្តល់សេវាទាំងនេះដល់អ្នកចុះបញ្ជី

៤. ផ្តល់ព័ត៌មានអំពីអ្នកមានសមត្ថកិច្ចផ្តល់សេវាដល់អ្នកត្រូវការប្រើប្រាស់

៥. ជ្រើសរើស និងកំណត់គ្រឹះស្ថានឧត្តមសិក្សា ឬវិទ្យាស្ថានបច្ចេកទេសនៅកម្ពុជា ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលជំនាញដែលជាមូលដ្ឋានអាចស្នើសុំចុះបញ្ជីនៅក្រសួងរ៉ែ និងថាមពល

៦. ជំរុញឱ្យការផ្តល់សេវារបស់អ្នកចុះបញ្ជី ឱ្យកាន់តែមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព និងការទទួលខុសត្រូវច្បាស់លាស់

៧. ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការងារផ្តល់សេវារបស់អ្នកចុះបញ្ជី។

## ជំពូកទី៣
## នីតិវិធីនៃការចុះបញ្ជី

**ប្រការ ៥**.-

លិខិតស្នើសុំចុះបញ្ជីជាអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវដាក់នៅការិយាល័យច្រកចេញចូលតែមួយ នៃក្រសួងរ៉ែ និងថាមពល។

**ប្រការ ៦.-**

ការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល និងអ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ត្រូវអនុវត្តតាមនីតិវិធីបង្ហាញក្នុងគំនូសបំព្រួញដូចខាងក្រោម៖



**ប្រការ ៧.-**

ការចុះបញ្ជីជាក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ និងកែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ត្រូវអនុវត្តតាមនីតិវិធីបង្ហាញក្នុងគំនូសបំព្រួញដូចខាងក្រោម៖




**ប្រការ ៨.-**

ក្រសួងរ៉ែ និងថាមពល ផ្តល់វិញ្ញាបនបត្រចុះបញ្ជីជាអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល លុះត្រាតែរូបវន្តបុគ្គល និងក្រុមហ៊ុនបានបំពេញបែបបទស្នើសុំចុះបញ្ជី ទៅតាមនីតិវិធី និងទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងប្រកាសនេះ។

## ជំពូកទី៤
## លក្ខខណ្ឌតម្រូវនៃអ្នកចុះបញ្ជី

**ប្រការ ៩**.-

អ្នកគ្រប់គ្រងថាមពល ត្រូវបំពេញលក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំវិញ្ញាបនបត្រចុះបញ្ជីដូចខាងក្រោម៖

- ត្រូវមានបរិញ្ញាបត្រវិស្វកម្ម ឬមានសញ្ញាបត្រសមមូល ឬខ្ពស់ជាង
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងការងារថាមពលតាមការកំណត់ក្នុងនីតិវិធី ឬមានវិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាល ឬលិខិតបញ្ជាក់ប្រលងជាប់ជាស្ថាពរលើវគ្គបណ្តុះបណ្តាលការគ្រប់គ្រងថាមពលពីគ្រឹះស្ថានឧត្តមសិក្សា ឬវិទ្យាស្ថាននៅកម្ពុជាដែលបានសហការរៀបចំជាមួយក្រសួងរ៉ែ និងថាមពល។

**ប្រការ ១០**.-

សវនករថាមពល ត្រូវបំពេញលក្ខខណ្ឌតម្រូវសម្រាប់ស្នើសុំវិញ្ញាបនបត្រចុះបញ្ជី ដូចខាងក្រោម៖

- ត្រូវមានបរិញ្ញាបត្រវិស្វកម្ម ឬមានសញ្ញាបត្រសមមូល ឬខ្ពស់ជាងក្នុងវិស័យថាមពល
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ថាមពលតាមការកំណត់ក្នុងនីតិវិធី ឬមានវិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាល ឬលិខិតបញ្ជាក់ប្រលងជាប់ជាស្ថាពរលើវគ្គបណ្តុះបណ្តាលការងារសវនកម្មថាមពល ពីគ្រឹះស្ថានឧត្តមសិក្សា ឬវិទ្យាស្ថាននៅកម្ពុជា ដែលបានសហការរៀបចំជាមួយក្រសួងរ៉ែ និងថាមពល។

**ប្រការ ១១**.-

អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពលចែកចេញជា ៣ (បី) កម្រិត និងត្រូវបំពេញលក្ខខណ្ឌតម្រូវសម្រាប់ស្នើសុំវិញ្ញាបនបត្រចុះបញ្ជី ដូចខាងក្រោម៖

១. កម្រិតវិស្វករ

- ត្រូវមានបរិញ្ញាបត្រវិស្វកម្ម ឬមានសញ្ញាបត្រសមមូល ឬខ្ពស់ជាង
- មានបទពិសោធន៍ធ្វើការងារជាវិស្វករក្នុងវិស័យថាមពលតាមការកំណត់ក្នុងនីតិវិធីអ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ឬមានវិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាល ឬលិខិតបញ្ជាក់ប្រលងជាប់ជាស្ថាពរវគ្គបណ្តុះបណ្តាល ពីគ្រឹះស្ថានឧត្តមសិក្សា ឬវិទ្យាស្ថាននៅកម្ពុជាដែលបានសហការរៀបចំជាមួយក្រសួងរ៉ែ និងថាមពល។

២. កម្រិតអ្នកបច្ចេកទេស

- ត្រូវមានបរិញ្ញាបត្ររងវិស្វកម្ម ឬមានសញ្ញាបត្រសមមូល
- មានបទពិសោធន៍ធ្វើការងារជាអ្នកបច្ចេកទេសក្នុងវិស័យថាមពលតាមការកំណត់ក្នុងនីតិវិធីអ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ឬមានវិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាល ឬលិខិតបញ្ជាក់ប្រលងជាប់ជាស្ថាពរវគ្គបណ្តុះបណ្តាលពីគ្រឹះស្ថានឧត្តមសិក្សា ឬវិទ្យាស្ថាននៅកម្ពុជាដែលបានសហការរៀបចំជាមួយក្រសួងរ៉ែ និងថាមពល។

៣. កម្រិតកម្មករជំនាញ

- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលជំនាញពីស្ថាប័នមានសមត្ថកិច្ច
- មានការយល់ដឹងអំពីបច្ចេកទេស និងដំណើរការការងារប្រព័ន្ធថាមពល។

**ប្រការ ១២.-**

ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ត្រូវបំពេញលក្ខខណ្ឌតម្រូវសម្រាប់ស្នើសុំវិញ្ញាបនបត្រចុះបញ្ជី ដូចខាងក្រោម៖

- មានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- មានប័ណ្ណពន្ធប៉ាតង់
- មានរចនាសម្ព័ន្ធគ្រប់គ្រង រួមមាន អ្នកគ្រប់គ្រងទូទៅ អ្នកគ្រប់គ្រងបច្ចេកទេស អ្នកបច្ចេកទេស និងកម្មករជំនាញ។

**ប្រការ ១៣.-**

ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ត្រូវមាន៖

១. អ្នកគ្រប់គ្រងបច្ចេកទេសដែលជាអ្នកធ្វើការងារជំនាញក្នុងវិស័យថាមពលកម្រិតវិស្វករ

២. អ្នកបច្ចេកទេសដែលជាអ្នកធ្វើការងារជំនាញក្នុងវិស័យថាមពលកម្រិតអ្នកបច្ចេកទេស ឬខ្ពស់ជាង

៣. កម្មករជំនាញដែលជាអ្នកធ្វើការងារជំនាញក្នុងវិស័យថាមពលកម្រិតកម្មករជំនាញ ឬខ្ពស់ជាង។

**ប្រការ ១៤.-**

ក្រុមហ៊ុនសញ្ជាតិបរទេស ដែលបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងស្នើសុំវិញ្ញាបនបត្រចុះបញ្ជីនៅក្រសួងរ៉ែ និងថាមពល ត្រូវបំពេញលក្ខខណ្ឌតម្រូវដូចគ្នានឹងក្រុមហ៊ុនសញ្ជាតិខ្មែរដែរ។

## ជំពូកទី៥

## សុពលភាព ការបន្តសុពលភាព ការព្យួរ និងការដកហូតវិញ្ញាបនបត្រចុះបញ្ជី

**ប្រការ ១៥.-**

សុពលភាព នៃវិញ្ញាបនបត្រចុះបញ្ជីដែលចេញដោយក្រសួងរ៉ែ និងថាមពល ត្រូវមាន៖

- សុពលភាព ៥ (ប្រាំ) ឆ្នាំ និងអាចស្នើសុំបន្តរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង សម្រាប់អ្នកគ្រប់គ្រងថាមពល សវនករថាមពល ឬអ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល។
- សុពលភាព ៧ (ប្រាំពីរ) ឆ្នាំ និងអាចស្នើសុំបន្តរយៈពេល ៧ (ប្រាំពីរ) ឆ្នាំម្តង សម្រាប់ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល។

វិញ្ញាបនបត្រនេះត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីមកក្រសួងរ៉ែ និងថាមពល យ៉ាងតិចបំផុតរយៈពេល ៣ (បី) ខែមុនថ្ងៃផុតសុពលភាព។

**ប្រការ ១៦.-**

វិញ្ញាបនបត្រចុះបញ្ជីអាចនឹងត្រូវបានព្យួរចាប់ពីរយៈពេល ៦ (ប្រាំមួយ) ខែ ដល់ ៣(បី) ឆ្នាំ ក្នុងករណីណាមួយដូចខាងក្រោម៖

- មានកំហុសដោយធ្វេសប្រហែសនៅក្នុងការធ្វើសេវាកម្មដំឡើង ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធថាមពល ឬសេវាកម្មដំណោះស្រាយថាមពល
- មិនបានរៀបចំផែនការសកម្មភាព និងការអនុវត្តការងារបច្ចេកទេស សុវត្ថិភាព និងបទដ្ឋានបច្ចេកទេសឱ្យបានត្រឹមត្រូវ និងច្បាស់លាស់

**ប្រការ ១៧.-**

វិញ្ញាបនបត្រចុះបញ្ជីអាចនឹងត្រូវដកហូតក្នុងករណីដូចខាងក្រោម៖

- នៅតែបំពានលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ
- សេវាកម្មដំឡើង ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធថាមពល ឬសេវាកម្មដំណោះស្រាយថាមពល ដែលបានផ្តល់ជូនអ្នកប្រើប្រាស់ថាមពល មិនគោរពតាមបទដ្ឋានបច្ចេកទេស និងសុវត្ថិភាព
- ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយ ។

**ប្រការ ១៨.-**

នីតិបុគ្គល និងរូបវន្តបុគ្គលមិនត្រូវបានអនុញ្ញាតឱ្យដាក់លិខិតស្នើសុំចុះបញ្ជីឡើងវិញបានឡើយ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីវិញ្ញាបនបត្រចុះបញ្ជីត្រូវបានដកហូត។

## ជំពូកទី៦
## កម្រៃសេវាសាធារណៈ

**ប្រការ ១៩.-**

អ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ដែលបានស្នើសុំវិញ្ញាបនបត្រចុះបញ្ជី ឬបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីនៅក្រសួងរ៉ែ និងថាមពល ត្រូវបង់កម្រៃសេវាសាធារណៈ អនុលោមភាពតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ ២០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២១.-**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានថាមពល ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១៣កើត ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ_រតនៈ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត
- ដូចប្រការ ២១ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១

## ទម្រង់លិខិតស្នើសុំ សម្រាប់ការស្នើសុំវិញ្ញាបនបត្រចុះបញ្ជីជាអ្នកគ្រប់គ្រងថាមពល ឬសវនករថាមពល ឬអ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កម្មវត្ថុៈ** សំណើសុំវិញ្ញាបនបត្រចុះបញ្ជីជា (*អ្នកគ្រប់គ្រងថាមពល ឬសវនករថាមពល ឬអ្នកធ្វើការជំនាញក្នុងប្រព័ន្ធថាមពល*) ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ មានបំណងស្នើសុំវិញ្ញាបនបត្រចុះបញ្ជីក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល ស្របតាមប្រកាសស្តីពី "លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធអគ្គិសនី និង ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល" ដែលចេញដោយក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី.....ខែ.....ឆ្នាំ២០២...។ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជូនភ្ជាប់មកជាមួយនូវឯកសារសម្រាប់ស្នើសុំខាងលើ ដូចខាងក្រោមៈ

| | |
|---|---|
| ១. ច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិជាតិខ្មែរ ឬលិខិតឆ្លងដែន(ជនបរទេស) | ០១ច្បាប់ |
| ២. សញ្ញាបត្របរិញ្ញាបត្រជំនាញវិស្វកម្ម ឬសញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ | ០១ច្បាប់ |
| ៣. វិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាល ឬលិខិតបញ្ជាក់ប្រលងជាប់ជាស្ថាពរពីគ្រឹះស្ថានឧត្តមសិក្សា ឬវិទ្យាស្ថានបច្ចេកទេសនៅកម្ពុជា ដែលបានសហការជាមួយក្រសួងរ៉ែ និងថាមពល | ០១ច្បាប់ |
| ៤. ប្រវត្តិរូបសង្ខេប | ០១ច្បាប់ |
| ៥. រូបថតទំហំ៤ x ៦ | ០៣សន្លឹក |
| ៦. លិខិតបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា(ជនបរទេស) | ០១ច្បាប់ |
| ៧. លិខិតបញ្ជាក់មានសិទ្ធិប្រកបការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ជនបរទេស) | ០១ច្បាប់ |
| ៨. ឯកសារពាក់ព័ន្ធ និងបទពិសោធន៍ការងារលើជំនាញ | |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចចុះបញ្ជីឱ្យខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ.......................ខែ..............ឆ្នាំ....... .......ស័ក ព.ស.២៥៦.....

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ២០២.....

ហត្ថលេខាអ្នកស្នើសុំ

(ឈ្មោះ............. )

ក្រសួងរ៉ែ និង ថាមពល

**ឧបសម្ព័ន្ធទី ២**

**ទម្រង់លិខិតស្នើសុំ សម្រាប់ការស្នើសុំវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមហ៊ុន..........

លេខ៖..............

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កម្មវត្ថុ៖** សំណើសុំវិញ្ញាបនបត្រចុះបញ្ជីជា (*ក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ កែលម្អប្រព័ន្ធអគ្គិសនី ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល*) ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា (*ឈ្មោះក្រុមហ៊ុនស្នើសុំ*) មានបំណងស្នើសុំវិញ្ញាបនបត្រចុះបញ្ជីជា (*ក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ កែលម្អប្រព័ន្ធអគ្គិសនី ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពលជូនអ្នកប្រើប្រាស់អគ្គិសនី*) ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល ស្របតាមប្រកាសស្តីពី "លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល" ដែលចេញដោយក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី.....ខែ.....ឆ្នាំ២០២....។ (*ឈ្មោះក្រុមហ៊ុនស្នើសុំ*) សូមគោរពជូនភ្ជាប់មកជាមួយនូវឯកសារសម្រាប់ស្នើសុំខាងលើ ដូចខាងក្រោម៖

១. ព័ត៌មានលម្អិតរបស់ក្រុមហ៊ុន (អ្នកស្នើសុំ) ០១ច្បាប់

២. ឯកសារភ្ជាប់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីឱ្យ( *ឈ្មោះក្រុមហ៊ុនស្នើសុំ*) ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ......................ខែ..............ឆ្នាំ....... .......ស័ក ព.ស.២៥៦.....

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ...........ឆ្នាំ២០២.....

ប្រធាន ឬ នាយកក្រុមហ៊ុន

(ហត្ថលេខា និងត្រាក្រុមហ៊ុន)

# ឧបសម្ព័ន្ធទី ៣

## ឯកសារភ្ជាប់ សម្រាប់ស្នើសុំវិញ្ញាបនបត្រចុះបញ្ជីជាក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ កែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល

### ផ្នែកទី១៖ ព័ត៌មានលម្អិតរបស់ក្រុមហ៊ុនស្នើសុំ

| | | | |
|---|---|---|---|
| ១ | ឈ្មោះក្រុមហ៊ុន | ភាសាខ្មែរ | |
| | | ឡាតាំង | |
| ២ | អាសយដ្ឋានក្រុមហ៊ុន | | |
| | | □ ទីតាំងជួល | □ ម្ចាស់ទីតាំង |
| ៣ | លេខទំនាក់ទំនង | | |
| ៤ | អ៊ីម៉ែល | | |
| ៥ | គេហទំព័រ (បើមាន) | | |
| ៦ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន | លេខចុះបញ្ជី | |
| | | កាលបរិច្ឆេទចុះបញ្ជី | |
| ៧ | លេខប័ណ្ណប៉ាតង់ | | |
| ៨ | ចំនួនបុគ្គលិកសរុបបំរើការងារក្នុងផ្នែកជំនាញ (នាក់) | | |
| ៩ | បទពិសោធន៍ការងារពាក់ព័ន្ធលើផ្នែកជំនាញ (គិតជាឆ្នាំ) | | |

### ផ្នែកទី២៖ ឯកសារភ្ជាប់

| ល.រ | ឈ្មោះឯកសារ | ចំនួន |
|---|---|---|
| ១ | បញ្ជីឈ្មោះអ្នកគ្រប់គ្រងថាមពល ឬសវនករថាមពល ឬអ្នកធ្វើការជំនាញក្នុងប្រព័ន្ធថាមពល ពេញសិទ្ធ (រួមទាំងប្រវត្តិរូបសង្ខេប) | ០១ច្បាប់ |
| ២ | ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០១ច្បាប់ |
| ៣ | ច្បាប់ចម្លងប័ណ្ណប៉ាតង់ | ០១ច្បាប់ |
| ៤ | ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ (ជនបរទេស) | ០១ច្បាប់ |
| ៥ | ច្បាប់ចម្លងកិច្ចសន្យាការងាររវាងក្រុមហ៊ុន និងអ្នកជំនាញថាមពល | ០១ច្បាប់ |
| ៦ | ច្បាប់ចម្លងកិច្ចសន្យាជួលទីតាំង ឬប្លង់កម្មសិទ្ធិ | ០១ច្បាប់ |
| ៧ | ច្បាប់ចម្លងលក្ខន្តិកៈក្រុមហ៊ុន | ០១ច្បាប់ |
| ៨ | ផែនទី និងរូបថតទីតាំងរបស់ក្រុមហ៊ុន | ០១ច្បាប់ |
| ៩ | រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន (រួមទាំងអ្នកជំនាញថាមពល) | ០១ច្បាប់ |
| ១០ | រូបថតរបស់អ្នកស្នើសុំ (ម្ចាស់ក្រុមហ៊ុន) ទំហំ ៤ x ៦ | ០៣សន្លឹក |
| ១១ | ច្បាប់ចម្លងភស្តុតាងនៃការមានសាច់ប្រាក់ក្នុងធនាគាររយៈពេល ៣ខែចុងក្រោយ ដែលត្រូវមានសមតុល្យយ៉ាងតិច ២០ ០០០ ដុល្លាអាមេរិក មុនពេលដាក់ពាក្យស្នើសុំ | ០១ច្បាប់ |
| ១២ | ចំនួនគម្រោងថាមពល ឬអគ្គិសនី និងទីតាំងគម្រោងដែលក្រុមហ៊ុន ធ្លាប់បានដំឡើងរួចនៅក្នុង ឬ ក្រៅប្រទេសកម្ពុជា | ០១ច្បាប់ |

**ឧបសម្ព័ន្ធទី ៤**

**ទម្រង់លិខិតបដិសេធនៃការស្នើសុំវិញ្ញាបនបត្រចុះបញ្ជី**

ថ្ងៃ......................ខែ..............ឆ្នាំ....... .......ស័ក ព.ស.២៥៦.....

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ២០២.....

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ជម្រាបជូន**

**លោក/លោកស្រី**.......................... (**ឬ នាយកក្រុមហ៊ុន** ................................)

**កម្មវត្ថុ៖** ការបដិសេធសំណើសុំវិញ្ញាបនបត្រចុះបញ្ជីជា *(ក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ កែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល)* ។

**យោង៖** លិខិតចុះថ្ងៃទី..... ខែ..... ឆ្នាំ២០២..... របស់ (លោក/លោកស្រី ឬ លោកនាយក....................................)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក/លោកស្រីនាយក ជ្រាបថា ក្រសួងរ៉ែ និងថាមពល បានពិនិត្យសំណើសុំវិញ្ញាបនបត្រចុះបញ្ជីរបស់លោក/លោកស្រី (ឬ ឈ្មោះក្រុមហ៊ុន) ក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ កែលម្អប្រព័ន្ធថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពលរួចរាល់ ឃើញថា លោក/លោកស្រី (ឬ ឈ្មោះក្រុមហ៊ុន) ពុំទាន់បានបំពេញតាមគ្រប់លក្ខខណ្ឌតម្រូវដែលកំណត់ដោយប្រកាសរបស់ក្រសួងរ៉ែ និងថាមពលនៅឡើយ។ ចំណុចខ្វះខាតនេះ មានដូចខាងក្រោម៖

១........................................................................................................................................

២........................................................................................................................................

ដូច្នេះ ក្រសួងរ៉ែ និងថាមពល ពុំអាចចេញវិញ្ញាបនបត្រចុះបញ្ជីទទួលស្គាល់តាមការស្នើសុំខាងលើបានឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម (លោក/លោកស្រី ឬ លោកនាយក) ជ្រាបជាព័ត៌មាន។

សូម (លោក/លោកស្រី ឬ លោកនាយក) ទទួលនូវការរាប់អានពីខ្ញុំ។

**ឧបសម្ព័ន្ធទី ៥**

**ទម្រង់លិខិតវិញ្ញាបនបត្រចុះបញ្ជីជាអ្នកគ្រប់គ្រងថាមពល ឬសវនករថាមពល**
**ឬអ្នកធ្វើការជំនាញក្នុងប្រព័ន្ធថាមពល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(Logo ក្រសួង)
ក្រសួងរ៉ែ និងថាមពល
លេខ..............



# វិញ្ញាបនបត្រចុះបញ្ជី

CERTIFICATE OF ACCREDITATION REGISTRATION

**សូមបញ្ជាក់ថា**

| | | | |
|---|---|---|---|
| គោត្តនាម និងនាម | ៖ | ជិបហុង សារ៉ាស៊ី | សញ្ជាតិ ៖ ខ្មែរ |
| ថ្ងៃខែឆ្នាំកំណើត | ៖ | ០១ មករា ១៩៨៧ | |
| អាសយដ្ឋាន | ៖ | ផ្ទះលេខ.......ផ្លូវ........ភូមិ.........សង្កាត់........ខណ្ឌ........រាជធានីភ្នំពេញ | |
| លេខអត្តសញ្ញាណ | ៖ | MME-00001 | |
| ផុតសុពលភាព | ៖ | ....(៣១ មករា ២០២...)..... | |

បានចុះបញ្ជីជា (*អ្នកគ្រប់គ្រងថាមពល ឬសវនករថាមពល ឬអ្នកធ្វើការជំនាញក្នុងប្រព័ន្ធថាមពល*) ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល ស្របតាមប្រកាសស្ដីពី "លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្ដល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្ដល់សេវាដំណោះស្រាយថាមពល" ដែលចេញដោយក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី.....ខែ.....ឆ្នាំ២០២៤ និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

CERTIFIED THAT

| | | | |
|---|---|---|---|
| Surname and Name | : | CHIPHONG SARASY | Nationality : Khmer |
| Date of Birth | : | 01-January-1987 | |
| Address | : | #01, Street…………,………………….Phnom Penh | |
| Identification Number | : | MME-00001 | |
| Expired Date | : | ……(31 January 202….)…… | |

Is registered as (*Expertise/Energy Manager/Energy Auditor*) in the framework of energy sector management of the Ministry of Mines and Energy in accordance with the Prakas on "Conditions and Procedures for Registration of Electricity Installation Service Providers, Energy Service Company Providers and Expertise" issued by the Ministry of Mines and Energy on dated .......... 202... and effective from the date of signing.

រាជធានីភ្នំពេញ ថ្ងៃទី..............ខែ...........ឆ្នាំ២០២...
Phnom Penh date........../.........../ 202...
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
Minister of Mines and Energy
(ហត្ថលេខា និងត្រា)

**ឧបសម្ព័ន្ធទី ៦**

**ទម្រង់លិខិតវិញ្ញាបនបត្រចុះបញ្ជីជាក្រុមហ៊ុនផ្តល់សេវាដំឡើង ជួសជុល ថែទាំ កែលម្អប្រព័ន្ធ ថាមពល ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

( Logo ក្រសួង )

ក្រសួងរ៉ែ និងថាមពល

លេខ..............



# វិញ្ញាបនបត្រចុះបញ្ជីទទួលស្គាល់

CERTIFICATE OF ACCREDITATION REGISTRATION

**សូមបញ្ជាក់ថា**

| | | |
|---|---|---|
| សហគ្រាសឈ្មោះ | ៖ | .................. |
| អាសយដ្ឋាន | ៖ | ផ្ទះលេខ.......ផ្លូវ........ភូមិ.........សង្កាត់........ខណ្ឌ........រាជធានីភ្នំពេញ |
| សកម្មភាពអាជីវកម្ម | ៖ | .....( ឧ. សហគ្រាស អគ្គិសនី )...... |
| ម្ចាស់/តំណាងសហគ្រាស | ៖ | .................. សញ្ជាតិ ៖ ខ្មែរ |
| លេខអត្តសញ្ញាណ | ៖ | MME-ESCO-00001 |
| ផុតសុពលភាព | ៖ | ....( ៣១ មករា ២០២... )..... |

បានចុះបញ្ជីទទួលស្គាល់ជា ក្រុមហ៊ុនផ្តល់សេវា.......... ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល ស្របតាមប្រកាសស្តីពី "លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល" ដែលចេញដោយក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី.....ខែ.....ឆ្នាំ២០២... និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

CERTIFIED THAT

| | | |
|---|---|---|
| Enterprise's Name | ៖ | ................................................................ |
| Address | ៖ | #01, Street............,...................Phnom Penh |
| Main Business Activity | ៖ | ............( Ex.: Electricity Enterprise )................ |
| Owner Name | ៖ | ........................ Nationality: Khmer |
| Identification Number | ៖ | MME-ESCO-00001 |
| Expired Date | ៖ | ......( 31 January 202... )...... |

Is registered as **Energy Service Company** in the framework of energy sector management of the Ministry of Mines and Energy in accordance with the Prakas on "Conditions and Procedures for Registration of Electricity Installation Service Providers, Energy Service Company Providers and Expertise" issued by the Ministry of Mines and Energy on dated .......... 202... and effective from the date of signing.

រាជធានីភ្នំពេញ ថ្ងៃទី............ខែ............ឆ្នាំ២០២...

Phnom Penh date........./.........../ 202...

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

Minister of Mines and Energy

( ហត្ថលេខា និងត្រា )

# ឧបសម្ព័ន្ធទី ៧

# ទម្រង់លិខិតបណ្ណសម្គាល់ជាអ្នកគ្រប់គ្រងថាមពល ឬសវនករថាមពល ឬអ្នកធ្វើការជំនាញក្នុងប្រព័ន្ធថាមពល

**ក្រសួងរ៉ែ និងថាមពល**
MINISTRY OF MINES AND ENERGY

**បណ្ណសម្គាល់** ( Identification Card )

| | | |
|---|---|---|
| គោត្តនាម និងនាម | : | ជិបហុង សារ៉ាស៊ី |
| Surname and Name | : | CHIPHONG SARASY |
| អាសយដ្ឋាន | : | ផ្ទះលេខ....ផ្លូវ.....ខណ្ឌ.......ភ្នំពេញ |
| Address | : | #1, St. ......, Phnom Penh |
| លេខអត្តសញ្ញាណ | : | MME-00001 |
| Identification No. | : | |
| ផុតសុពលភាព | : | ៣១ មករា ២០២... |
| Expired Date | : | 31 January 202... |



បានចុះបញ្ជីទទួលស្គាល់ជា "អ្នកគ្រប់គ្រងថាមពល" ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យថាមពលរបស់ក្រសួងរ៉ែ និងថាមពល ស្របតាមប្រកាសស្ដីពី "លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនករថាមពល អ្នកធ្វើការងារជំនាញក្នុងប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុល កែលម្អប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល" ដែលចេញដោយក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី.....ខែ.....ឆ្នាំ២០២... ។

រាជធានីភ្នំពេញ ថ្ងៃទី............ខែ............ឆ្នាំ២០២...
Phnom Penh date......../.........../ 202...

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
Minister of Mines and Energy

( ហត្ថលេខា និងត្រា )